ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ០៩/០៩ —នីមប៊ីស ឌីចថាយ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ស៊ីន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន នីមប៊ីស ឌីចថាយ (ខេមបូឌា) ខូ អិលធីឌី**

អាសយដ្ឋាន : ភូមិព្រៃរកា ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១៦ ៦៧៧ ៧១៨ ឬ ០៩២ ៨៩៩ ៥៨៨ ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក :

| | | |
|---|---|---|
| ១- | លោក Wang Fu Qiang | អ្នកគ្រប់គ្រង |
| ២- | លោក អ៊ឹង កុកប៉ាង | Shipping |
| ៣- | លោក ញួង ឡេង | អ្នកបកប្រែ |

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សហព័ន្ធសហជីព-សហជីពយុវជនខ្មែរ ប្រចាំរោងចក្រ នីម ប៊ីស ឌីចថាយ**

អាសយដ្ឋាន : ភូមិព្រៃរកា ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល


មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៨៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 783
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

ទូរស័ព្ទ : ០១២ ៩០៦ ៨១១ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត : **អវត្តមាន**

## បញ្ជាក្តុងទីទាន

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ការធ្វើការបន្ថែមម៉ោងស្ថិតលើគោលការណ៍ស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ ឬ ចាត់វិធានការណ៍អ្វីមកលើកម្មករឡើយ ។

២- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានពេទ្យប្រចាំការរៀងរាល់ម៉ោងធ្វើការ ព្រមទាំងថ្នាំគ្រប់គ្រាន់ ។

៣- សុំក្រុមហ៊ុនបញ្ចូលកម្មករសាកល្បងចាប់ពី ២ខែឡើងទៅ ជាកម្មករពេញសិទ្ធិ និងផ្តល់អត្ថប្រយោជន៍ផ្សេងៗ តាមច្បាប់ស្តីពីការងារ (រំលឹកប្រាក់ឈ្នួលសារឡើងវិញ) ។

៤- សុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅកូន នៅក្នុងក្រុមហ៊ុន ។

៥- នៅពេលក្រុមហ៊ុនតម្រូវឱ្យធ្វើការថ្ងៃបុណ្យ ឬ ថ្ងៃអាទិត្យសុំបាយមួយពេល ។

៦- ចំពោះកម្មករថែមម៉ោងលើសពី ២ម៉ោង សុំឱ្យក្រុមហ៊ុនមានមធ្យោបាយជូនដល់ផ្ទះ ។

៧- សុំឱ្យក្រុមហ៊ុនសង់រោងបាយនៅក្នុងក្រុមហ៊ុន ដើម្បីឱ្យកម្មករជ្រកហូបបាយ ។

៨- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ២ដុល្លារអាមេរិកបន្ថែម ពោលគឺ ៧ដុល្លារអាមេរិកក្នុងមួយខែ ។ ហើយឈប់សម្រាកត្រឹមត្រូវ បីថ្ងៃកុំឱ្យកាត់អស់ ។

៩- សុំឱ្យក្រុមហ៊ុនបើកប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំ ២ដង ពោលគឺ ភ្ជុំ និងចូលឆ្នាំខ្មែរ ។

១០- សុំបើកលុយបាយមួយសប្តាហ៍ម្តង ។

១១- ពេលកម្មករឈឺហើយមានលិខិតបញ្ជាក់ពីពេទ្យត្រឹមត្រូវ សុំក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករ ។

១២- សុំឱ្យក្រុមហ៊ុនចែកកែវទឹក និងដាក់ទឹកក្តៅ ទឹកត្រជាក់ និងទឹកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ និងមានអនាម័យល្អ ។

១៣- នៅពេលក្រុមហ៊ុនគ្មានការងារធ្វើម្តងម្កាល សុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលគោលពេញ (រំលឹកសារឡើងវិញ) ។

១៤- សុំឱ្យក្រុមហ៊ុនផ្តល់ពេល ១៥នាទី សម្រាប់ឱ្យកម្មករមានធុរៈចេញក្រៅ ឬបងប្អូនមករកចាំបាច់ ។

១៥- សុំឱ្យក្រុមហ៊ុនណែនាំបុគ្គលិកផ្នែកចិន ឱ្យមានអត្តចរិកសមរម្យ ។

១៦- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលឱ្យរួចរាល់ក្នុងម៉ោង ៤ ជារៀងរាល់ខែ ។

១៧- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានធុងបាស់សម្រាប់ចាក់ឱ្យកម្មករស្តាប់ពេលបំពេញការងារ ។

១៨- ពេលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារកម្មករណាម្នាក់ សុំបើកអត្ថប្រយោជន៍ផ្សេងៗទៅតាមច្បាប់ស្តីពីការងារ ហើយរួចរាល់រយៈពេល ៤៨ម៉ោង ។

១៩- សុំឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ។

២០- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលមួយពាន់រៀល (១០០០រៀល)ពីកម្មករដែលជាសមាជិកសហជីពយុវជនខ្មែរ ដើម្បីបង់ភាគទានជូនសហជីពយុវជនខ្មែរ ។

២១- សុំឱ្យក្រុមហ៊ុនចាត់វិធានការណ៍ទៅតាមច្បាប់ ចំពោះរដ្ឋបាលដែលតែងតែគំរាមគំហែងមកលើកម្មករដែលចូលជាសមាជិកសហជីព ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០២១/០៩ ក.ប/កណ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក (ភាគីសហជីព និង កម្មករនិយោជិត អវត្តមាន) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួម ចំនួន២១ចំណុច ។ ប៉ុន្តែភាគីទាំងពីរបានឯកភាពលើកពេលចរចាទៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ។

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ២១ចំណុច ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៣ចំណុច ដោយហេតុថា ក្នុងពេលដំណើរការផ្សះផ្សាបានដល់ចំណុចវិវាទទី៥ ត្រូវបានរាំងស្ទះ ពីព្រោះសហព័ន្ធសហជីពយុវជនខ្មែរបានចោទប្រកាន់ក្រុមហ៊ុនថា អ្នកតំណាងក្រុមហ៊ុនពុំមានលិខិតផ្ទេរសិទ្ធិពីនាយកក្រុមហ៊ុនទេ ហើយគ្មានសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រេចកិច្ចការនេះឡើយ។ ដោយមូលហេតុនេះ ចំណុចវិវាទទាំង ២១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចវិវាទទាំង២១ចំណុចនេះ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទី ព្រឹក ប៉ុន្តែភាគីសហជីព កម្មករនិយោជិតមិនបានមកចូលរួមសវនាការ ហើយក៏មិនបានស្នើសុំជាលាយល័ក្ខណ៍អក្សរ ដើម្បីពន្យារពេលសវនាការ ដោយមានបញ្ជាក់ពីមូលហេតុត្រឹមត្រូវ ឱ្យបានមុនពេលសវនាការឡើយ។ ដល់ម៉ោងបើកសវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទៅភាគីសហជីព។ នៅពេលនោះ ភាគីសហជីពបានឆ្លើយតបមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ពួកគាត់មិនមកចូលរួមសវនាការទេ ហើយទោះបីមានសវនាការលើកក្រោយទៀត ក៏ពួកគាត់មិនមកចូលរួមសវនាការទៀតដែរ។ ចំណែកឯ ភាគីនិយោជកវិញ បានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអនុវត្តតាមច្បាប់។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម:

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក-ឯកសារបានទទួលពីភាគីនិយោជក :**

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៃក្រុមហ៊ុន នីមបឹស ធីចថាយ លេខ ៥០៣ ពណ.នតក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦។

២- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន នីម បឹស ធីចថាយ ចុះបញ្ជិកាលេខ ០១៩/០៦ ក.ប.វ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៦។

៣- លក្ខន្តិកៈក្រុមហ៊ុន នីម បឹស ធីចថាយ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន នីមបឹស ធីចថាយ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០០៩។

៥- សារណាស្តីពីព្រឹត្តិការណ៍ដែលកើតឡើងកន្លងមករបស់ក្រុមហ៊ុនវាយនភណ្ឌ នីម បឺស កម្ពុជា ។

៦- លិខិតរបស់កម្មករ កម្មការិនីនៃក្រុមហ៊ុន នីម បឺស គោរពជូន ប្រធានសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីសំណើរសុំជួយអន្តរាគមន៍ និង ដោះស្រាយនូវលក្ខខ័ណ្ឌការងារមួយចំនួន ។

៧- តារាងថែមម៉ោងស្ម័គ្រចិត្តចាប់ពីម៉ោង ១៨:៣០-២០:៣០ ។

៨- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរលេខ ៧៦៦ សសយខ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព និងគណៈកម្មាធិការសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន នីម បឺស ។

៩- លិខិតរបស់រោងចក្រ នីម បឺស គោរពជូន លោកអគ្គនាយកដ្ឋានការងារ ក្រុងភ្នំពេញ ស្តីពីការជូនដំណឹងបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព និងគណៈកម្មាធិការសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន នីម បឺស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១០- លិខិតលាលែងពីសហជីពយុវជនខ្មែររបស់ឈ្មោះ ហៀក គា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១១- លិខិតលាលែងពីសហជីពយុវជនខ្មែររបស់ឈ្មោះ យ៉ន ថៃ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១២- លិខិតលាលែងពីសហជីពយុវជនខ្មែររបស់ឈ្មោះ លាង ណាង ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១៣- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ ញូន រី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ។

១៤- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ នួន ចាន់ធឿន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៨ ។

១៥- ប្រវត្តិរូបសង្ខេបរបស់ឈ្មោះ ទឹម ចន្ថា ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន នីមបឺស ចិចថាយ លេខ ០២១ ក.ប/កណ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ក្រុមហ៊ុន នីមបឺស ចិចថាយ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥០ កប/អក/លកអ. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៩ កប/អក/លកអ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩។

**ការរកឃើញអង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារទាំងនេះទេ ដោយហេតុថា ភាគីសហជីព កម្មករនិយោជិតអវត្តមាននៅក្នុងថ្ងៃសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច**

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត បានទទួលលិខិតអញ្ជើញឱ្យមកចូលរួមក្នុងសវនាការត្រឹមត្រូវ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយសម្រេចចិត្តមិនមកចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ លើសពីនេះទៀត នៅពេលដល់ម៉ោងបើកសវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទៅភាគីសហជីព ស្រាប់តែពេលនោះ ភាគីសហជីពបានឆ្លើយតបថា ពួកគាត់មិនមកចូលរួមសវនាការទេ ហើយទោះបីមានសវនាការលើកក្រោយទៀត ក៏ពួកគាត់មិនមកចូលរួមសវនាការទៀតដែរ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម:

វិធាន ៤.៧ ឧបសម្ព័ន្ធ ៣ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល យោងតាមប្រការ ៣១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល សកបយ. ចុះថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាល អាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ។ ក្នុងករណីណាមួយក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃ ដំណើរការអាជ្ញាកណ្តាល មុនពេល ធ្វើសេចក្តីសម្រេចរបស់ខ្លួន "* ។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ "* ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសគី លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣ លេខ ៩៥/០៨-យ៉ុង វ៉ា ទី១ លេខ ១៣២/០៨-ជី អេច ជី លេខ ១៣៨/០៨-ម៉ាលើន និងលេខ ១៩១/០៨-វិល ស៊ិន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបិទសំណុំរឿងបាន *" លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងត្រឹមត្រូវ**

ដោយផ្អែកលើចំណុច (ឃ) ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើលិខិតអញ្ជើញភាគីសហជីព កម្មករនិយោជិត ឱ្យមកចូលរួមសវនាការ ហើយមុនពេលសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទូរស័ព្ទរំលឹកដល់ភាគីសហជីព កម្មករនិយោជិត ដើម្បីមកចូលរួមសវនាការឱ្យទាន់តាមពេលវេលាកំណត់។ ប៉ុន្តែភាគីកម្មករនិយោជិតបានឆ្លើយថា មិនមកចូលរួមសវនាការទេ ហើយទោះបីមានសវនាការលើកក្រោយទៀត ក៏ពួកគាត់មិនមកចូលរួមសវនាការដែរ ទោះបីជាទទួលបានដំណឹងអំពីកាលបរិច្ឆេទសវនាការ ពេលវេលា និងទីកន្លែងសវនាការរួចហើយ ស្របតាមវិធាន ៤.៧ ដែលជាឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព កម្មករនិយោជិត ពិតជាបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសវនាការប្រាកដមែន ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី ២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា **"ពាក្យបង្ហាញខ្លួនក្នុងសវនាការ"** ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។

ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី។

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត មិនបានបង្ហាញខ្លួននៅក្នុងសវនាការតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។**

**លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានផ្តល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះមកដល់ថ្ងៃសវនាការ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ០៨:០០ នាទីព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើទំនាក់ទំនងតាមទូរស័ព្ទរំលឹក ទៅភាគីនិយោជក និងភាគីសហជីព កម្មករនិយោជិត ស្រាប់តែភាគីសហជីព កម្មករនិយោជិតបានឆ្លើយថា ពួកគាត់មិនមកចូលរួមសវនាការទេ ហើយក៏មិនបានផ្តល់មូលហេតុអំពីការមិនបានចូលរួមដែរ។ ចំណែកឯ ភាគីក្រុមហ៊ុនបានមកចូលរួមក្នុងសវនាការតាមកាលកំណត់ និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអនុវត្តតាមច្បាប់។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា **ភាគីសហជីពកម្មករនិយោជិតមិនបាន ផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។**

ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

ផ្អែកតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងប្រកាសលេខ ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីភាគីសហជីព កម្មករនិយោជិត មិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សហជីពយុវជនខ្មែរ ប្រចាំរោងចក្រ នីមប៊ីស ថិចថាយ ដែលជាភាគីដើមបណ្តឹង ក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ សហជីពបានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាងដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹង មិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណីភាគីដើមបណ្តឹង មិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីសហជីព កម្មករនិយោជិត ក្នុងការយកវិវាទការងាររបស់ខ្លួន មកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងលេខ ០៩/០៩-នីមប៊ីស ថិចថាយ នេះ។



Mea

យោងតាមហេតុផល និង អង្គច្បាប់ ដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## **សម្រេច និង បង្គាប់**

- បិទសំណុំរឿងលេខ ០៩/០៩-នីមបឹស ចិចថាយ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុំ សុន្ទី**

ហត្ថលេខា: --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ស៊ុន គឹមស៊ាន**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: --------------------------------